**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ :** ០៤៥/២០ **ក.ប**/ស.ណ.ន.ខ.ល

# សេចក្តីណែនាំ
# ស្តីពី
# ការព្យួរកិច្ចសន្យាការងារ និងការផ្អាកបង់ភាគទាន ប.ស.ស. សម្រាប់រោងចក្រ សហគ្រាស គ្រឹះស្ថានក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារជំងឺកូវីដ-១៩

យោងសេចក្តីប្រកាសព័ត៌មាន ស្តីពីសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីវិធានការបន្ថែមសំដៅជួយដល់វិស័យឯកជន និងកម្មករនិយោជិតដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីការរីករាលដាលនៃជំងឺកូវីដ-១៩ (ជុំទី៣ ថ្ងៃទី៧ ខែមេសា ឆ្នាំ២០២០) និងយោងច្បាប់ស្តីពីការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមណែនាំដល់ (១) ម្ចាស់ ឬនាយករោងចក្រ សហគ្រាស គ្រឹះស្ថានក្នុងវិស័យកាត់ដេរ (រួមមានរោងចក្រវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប) និងវិស័យទេសចរណ៍ ក្នុងដែនរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តកែប និងខេត្តកំពត (រួមមានសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងភ្នាក់ងារទេសចរណ៍) ដែលខ្វះវត្ថុធាតុដើម ឬគ្មានការបញ្ជាទិញ ឬមិនមានទីផ្សារនាំចេញ ឬពុំមានអតិថិជនប្រើប្រាស់សេវា ឬមានការលំបាកជាពិសេសណាមួយ ដែលនាំឱ្យព្យួរសកម្មភាពផលិតកម្ម ឬអាជីវកម្មជាបណ្តោះអាសន្ន និង(២) បងប្អូនកម្មករនិយោជិតដែលបម្រើការងារនៅក្នុងរោងចក្រ សហគ្រាស គ្រឹះស្ថានទាំងនោះ ត្រូវរួមគ្នាជាដាច់ខាតបំពេញនូវនីតិវិធីនៃការព្យួរកិច្ចសន្យាការងារ និងការស្នើសុំផ្អាកបង់ភាគទានបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) ដូចខាងក្រោម៖

## ក-ការស្នើសុំព្យួរកិច្ចសន្យាការងារ

ក១-សម្រាប់ម្ចាស់ ឬនាយករោងចក្រ សហគ្រាស គ្រឹះស្ថានក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍ ដែលមិនទាន់បានធ្វើបច្ចុប្បន្នភាពមកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កាលពីចុងខែមីនា ឆ្នាំ២០២០ ត្រូវ៖

- ដាក់លិខិតស្នើសុំព្យួរកិច្ចសន្យាការងារមករដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈនាយកដ្ឋានអធិការកិច្ចការងារ សម្រាប់រោងចក្រ សហគ្រាស គ្រឹះស្ថាន ដែលមានទីតាំងនៅរាជធានីភ្នំពេញ និងតាមរយៈមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត សម្រាប់រោងចក្រ សហគ្រាស គ្រឹះស្ថាន ដែលមានទីតាំងនៅបណ្តាខេត្ត តាមទម្រង់លិខិតដូចមានក្នុង**ឧបសម្ព័ន្ធទី១ និងទី២** នៃសេចក្តីណែនាំនេះ និងអាចស្វែងរកបាននៅក្នុងគេហទំព័ររបស់ក្រសួង www.mlvt.gov.kh។

រយៈពេលព្យួរកិច្ចសន្យាការងារជាអតិបរមាគឺចំនួន ២ខែ និងអាចពន្យារបន្ថែមក្នុងករណីចាំបាច់ និងស្ថានភាពជាក់ស្តែង។

សូមទាញយកឯកសារតាម **QR Code** នេះ
ឬតាម Link នេះ https://bit.ly/3bHZ6Bv



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩

- ផ្សព្វផ្សាយ និងជូនដំណឹងឱ្យបានទូលំទូលាយ និងជាចំហដល់កម្មករនិយោជិត ដែលត្រូវព្យួរកិច្ចសន្យាការងារឱ្យផ្តល់ជាដាច់ខាតនូវ (១) លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និង(២) លេខទូរស័ព្ទផ្ទាល់ខ្លួន (ឬលេខទូរស័ព្ទសាច់ញាតិបង្កើត) ដើម្បីក្រសួងយកទៅធ្វើជាមូលដ្ឋានសម្រាប់ផ្ទេរប្រាក់ឧបត្ថម្ភចំនួន ៤០ដុល្លារអាមេរិក ក្នុង១ខែ តាមរយៈធនាគារឯកទេសវីង។
- រៀបចំបញ្ជីរាយនាមកម្មករនិយោជិត ដែលត្រូវព្យួរកិច្ចសន្យាការងារឱ្យបានត្រឹមត្រូវទាំងស្រុង តាមទម្រង់ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៣ នៃសេចក្តីណែនាំនេះ ដោយតម្រូវឱ្យកម្មករនិយោជិត ផ្តិតមេដៃនៅលើឈ្មោះរបស់ខ្លួន ដើម្បីបញ្ជាក់ថា លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលេខទូរស័ព្ទដែលរោងចក្រ សហគ្រាស គ្រឹះស្ថានបានរៀបចំនេះ គឺត្រឹមត្រូវ។

  ម្ចាស់ ឬនាយករោងចក្រ សហគ្រាស គ្រឹះស្ថាន ដែលខកខានក្នុងការផ្សព្វផ្សាយជាចំហដល់កម្មករនិយោជិត ជ្រាបអំពីតម្រូវការព័ត៌មានខាងលើនេះ ឬខកខានក្នុងការឱ្យកម្មករនិយោជិត ផ្តិតមេដៃទទួលស្គាល់លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលេខទូរស័ព្ទ ដែលខ្លួនបានចងក្រង រួចនោះ ត្រូវទទួលខុសត្រូវបង់ជូនកម្មករនិយោជិតនោះ នូវប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល ដែលមានចំនួន ៤០ដុល្លារអាមេរិក ក្នុង១ខែនោះ។
- ភ្ជាប់មកជាដាច់ខាតច្បាប់ថតចម្លងឯកសារនីមួយៗចំនួន ៣ច្បាប់ នូវ (១) បញ្ជីបើកប្រាក់ឈ្នួលចុងក្រោយមុនពេលព្យួរកិច្ចសន្យាការងារ ដោយមានបោះត្រារបស់រោងចក្រ សហគ្រាស គ្រឹះស្ថាននៅគ្រប់ទំព័រ, (២) វិញ្ញាបនបត្រពាណិជ្ជកម្ម, (៣) អាជ្ញាប័ណ្ណទេសចរណ៍ (សម្រាប់វិស័យទេសចរណ៍), (៤) ប័ណ្ណពន្ធប៉ាតង់, (៥) វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថានក្នុង ប.ស.ស. (បើមាន), និង (៦) លេខគណនីធនាគាររបស់រោងចក្រ សហគ្រាស គ្រឹះស្ថាន។

ក្រោយទទួលបានលិខិតស្នើសុំព្យួរកិច្ចសន្យាការងារ ដោយមានឯកសារយោងគ្រប់គ្រាន់ អធិការការងារនឹងចុះទៅពិនិត្យ និងផ្ទៀងផ្ទាត់នៅតាមរោងចក្រ សហគ្រាស គ្រឹះស្ថាននោះ ក្នុងអំឡុងពេល ២ថ្ងៃ នៃថ្ងៃធ្វើការ។

**ក២-សម្រាប់ម្ចាស់ ឬនាយករោងចក្រ សហគ្រាស គ្រឹះស្ថានក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍ ដែលបានធ្វើបច្ចុប្បន្នភាពមកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬតាមរយៈមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រួចហើយ កាលពីចុងខែមីនា ឆ្នាំ២០២០ ត្រូវ៖**

- អនុវត្តដូចនីតិវិធី ដែលមានចែងនៅក្នុងចំណុច ក១ ខាងលើទាំងស្រុង ប៉ុន្តែត្រូវអនុវត្តតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម https://suspension.mlvt.gov.kh ដែលមានសេចក្តីណែនាំអំពីរបៀបប្រើប្រាស់ប្រព័ន្ធនេះ ដូចមានក្នុងឧបសម្ព័ន្ធទី៤ នៃសេចក្តីណែនាំនេះ។

**ក៣-កាតព្វកិច្ចផ្សេងទៀតរបស់ម្ចាស់ ឬនាយករោងចក្រ សហគ្រាស គ្រឹះស្ថានក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍៖**

- សម្រាប់រោងចក្រ សហគ្រាស គ្រឹះស្ថានក្នុងវិស័យកាត់ដេរ ត្រូវផ្តល់ប្រាក់ឧបត្ថម្ភចំនួន ៣០ដុល្លារអាមេរិក សម្រាប់កម្មករនិយោជិតម្នាក់ៗ ក្នុង១ខែ ក្នុងនោះ៖
  - ចំនួន ១០ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
  - ចំនួន ២០ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
  - ចំនួន ៣០ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ២១ថ្ងៃ ដល់ ១ខែ។
- សម្រាប់សហគ្រាស គ្រឹះស្ថានក្នុងវិស័យទេសចរណ៍ ត្រូវពិនិត្យផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមដល់កម្មករនិយោជិត តាមលទ្ធភាពនិងការស្ម័គ្រចិត្ត នៅក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារ ព្រមទាំងកំណត់នីតិវិធីនៃការបើកប្រាក់ឧបត្ថម្ភបន្ថែមនេះ។

- ត្រូវអនុវត្តការព្យួរកិច្ចសន្យាការងារ តាមកាលបរិច្ឆេទ និងរយៈពេល ដែលមានកំណត់នៅក្នុងលិខិតអនុញ្ញាតឱ្យព្យួរកិច្ចសន្យាការងាររបស់ក្រសួង។ ក្នុងករណីត្រូវបញ្ចប់ការព្យួរកិច្ចសន្យាការងារ (ចូលធ្វើការងារវិញ) មុនកាលកំណត់ ដែលមានចែងនៅក្នុងលិខិតអនុញ្ញាតព្យួរកិច្ចសន្យាការងារ ត្រូវធ្វើលិខិតជូនដំណឹងមករដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈនាយកដ្ឋានអធិការកិច្ចការងារ ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តឱ្យបានយ៉ាងតិច ២ថ្ងៃ (នៃថ្ងៃធ្វើការ) មុនថ្ងៃចូលធ្វើការវិញ តាមទម្រង់លិខិតដូចមានក្នុងឧបសម្ព័ន្ធទី៥ និងទី៦ នៃសេចក្តីណែនាំនេះ។
- ទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាននូវរាល់ព័ត៌មាន ដែលបានផ្តល់មកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងត្រូវសងមករាជរដ្ឋាភិបាលវិញ ចំពោះការឃុបឃិតក្លែងបន្លំព័ត៌មានណាមួយ។

**ក៤-សម្រាប់កម្មករនិយោជិត ត្រូវ៖**

- ផ្តល់លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលេខទូរស័ព្ទផ្ទាល់ខ្លួនដែលអាចទាក់ទងបាន ដល់ម្ចាស់ ឬនាយករោងចក្រ សហគ្រាស គ្រឹះស្ថានក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍ ដើម្បីចងក្រងជាបញ្ជីផ្តល់ជូនក្រសួង យកទៅរៀបចំនីតិវិធីបើកផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលដែលមានចំនួន ៤០ដុល្លារអាមេរិក ក្នុង១ខែ តាមរយៈធនាគារឯកទេសវីង ទៅកម្មករនិយោជិត។

  ប្រសិនបើគ្មានលេខទូរស័ព្ទផ្ទាល់ខ្លួន ត្រូវផ្តល់លេខទូរស័ព្ទជារបស់ប្តី ប្រពន្ធ កូន ឪពុក ម្តាយ ឬបងប្អូនបង្កើត និងមិនត្រូវផ្លាស់ប្តូរលេខទូរស័ព្ទជាដាច់ខាត។
- ទទួលបានប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាល តាមរយៈភ្នាក់ងារវីង ដូចខាងក្រោម៖
  - ចំនួន ១៥ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
  - ចំនួន ៣០ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
  - ចំនួន ៤០ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ២១ថ្ងៃ ដល់ ១ខែ។
- ក្រោយពេលព្យួរកិច្ចសន្យាការងារចំនួន ១០ថ្ងៃ កម្មករនិយោជិត នឹងទទួលបានសារតាមទូរស័ព្ទពីធនាគារឯកទេសវីង ដែលជម្រាបដំណឹងអំពីចំនួនទឹកប្រាក់ដែលត្រូវទទួលបាន។
- ក្រោយពេលទទួលបានសារជូនដំណឹងតាមទូរស័ព្ទ សូមបងប្អូនយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរស័ព្ទដែលទទួលបានសារនោះ ទៅភ្នាក់ងារវីងណាមួយ ដែលនៅជិតផ្ទះបងប្អូនបំផុត ដើម្បីបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលនោះ។ ធនាគារឯកទេសវីង នឹងបង្វិលថវិកានោះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនណាម្នាក់ខកខានទៅបើកប្រាក់ឧបត្ថម្ភនោះ ក្នុងរយៈពេល ១០ថ្ងៃ ក្រោយពីធនាគារឯកទេសវីង បានផ្ញើសារតាមទូរស័ព្ទជូនបងប្អូន។

ក្រសួងសូមក្រើនរំលឹកដល់កម្មករនិយោជិត ត្រូវសហការផ្តល់លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលេខទូរស័ព្ទដែលអាចទំនាក់ទំនងបាន ទៅរោងចក្រ សហគ្រាស គ្រឹះស្ថានជាដាច់ខាត ព្រមទាំងត្រូវពិនិត្យលេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលេខទូរស័ព្ទ ដែលមាននៅក្នុងតារាងបញ្ជីឈ្មោះកម្មករនិយោជិតត្រូវព្យួរកិច្ចសន្យាការងារឱ្យបានត្រឹមត្រូវ មុននឹងផ្តិតមេដៃបញ្ជាក់អំពីភាពត្រឹមត្រូវនៃព័ត៌មានទាំងពីរនេះ។

កម្មករនិយោជិតណាម្នាក់ ដែលខកខានក្នុងការផ្តល់លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលេខទូរស័ព្ទដល់រោងចក្រ សហគ្រាស គ្រឹះស្ថាន គឺមានន័យថាសាមីខ្លួនបានស្ម័គ្រចិត្តមិនទទួលយកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលដែលមានចំនួន ៤០ដុល្លារអាមេរិក ក្នុង១ខែនេះទេ។

ក៥-សម្រាប់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- ត្រូវចម្លងលិខិតអនុញ្ញាតព្យួរកិច្ចសន្យាការងារ តាមទម្រង់លិខិតដូចមានក្នុងឧបសម្ព័ន្ធទី៧ និងទី៨ នៃសេចក្តីណែនាំនេះដល់ក្រសួងពាណិជ្ជកម្ម, ក្រសួងទេសចរណ៍ (ពាក់ព័ន្ធវិស័យទេសចរណ៍), ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងរ៉ែ និងថាមពល, ធនាគារជាតិនៃកម្ពុជា, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, បេឡាជាតិសន្តិសុខសង្គម និងរដ្ឋបាលរាជធានី ខេត្ត ដែលពាក់ព័ន្ធ។

**ខ-ការស្នើសុំផ្អាកបង់ភាគទាន និងការបន្តផ្តល់អត្ថប្រយោជន៍របស់ ប.ស.ស.**

- ម្ចាស់ ឬនាយករោងចក្រ សហគ្រាស គ្រឹះស្ថាន ដែលជាសមាជិក ប.ស.ស. ត្រូវធ្វើលិខិតជូនដំណឹងអំពីការផ្អាកបង់ភាគទានមក ប.ស.ស. តាមទម្រង់លិខិតដូចមានក្នុងឧបសម្ព័ន្ធទី៩ នៃសេចក្តីណែនាំនេះ និងអាចស្វែងរកបាននៅក្នុងគេហទំព័ររបស់ក្រសួង www.mlvt.gov.kh។
- ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារ កម្មករនិយោជិតនឹងបន្តទទួលបានតាវកាលិកផ្នែកថែទាំសុខភាពពី ប.ស.ស.។
- កម្មករនិយោជិតនៅតែបន្តទទួលប្រាក់ឧបត្ថម្ភសម្រាប់ពេលសម្រាលកូនពីរាជរដ្ឋាភិបាល (៤០ម៉ឺនរៀលសម្រាប់កូនម្នាក់, ៨០ម៉ឺនរៀលសម្រាប់កូនភ្លោះពីរនាក់, និង១,២លានរៀលសម្រាប់កូនភ្លោះបីនាក់ និងទទួលបានប្រាក់ឧបត្ថម្ភរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ចំនួន ៥លានរៀល)។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងៈ លោក អ៊ុក ចាន់ធូ (012 872 161), លោក ហួន សុខភានាថ (089 676 821), លោក ម៉ាញ ណារិទ្ធ (087 525 656), និងលោក ឌឹម ឧត្តម (092 208 797)។

ម្ចាស់ ឬនាយករោងចក្រ សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតនៃវិស័យកាត់ដេរ ដែលរួមមាន រោងចក្រវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប និងវិស័យទេសចរណ៍ ក្នុងដែនរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តព្រះសីហនុ ខេត្តកែប និងខេត្តកំពត ដែលរួមមានសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងភ្នាក់ងារទេសចរណ៍ ត្រូវចូលរួមអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ១០ រោច ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០២០

រដ្ឋមន្ត្រី

**អ៊ិត សំហេង**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងទេសចរណ៍
- ក្រសួងរ៉ែ និងថាមពល
- ធនាគារជាតិនៃកម្ពុជា
- អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋបាលរាជធានី ខេត្ត

  "ដើម្បីជូនជ្រាប"
- ឯកសារ កាលប្បវត្តិ

*ឧបសម្ព័ន្ធទី១៖ លិខិតស្នើសុំព្យួរកិច្ចសន្យាការងារនៅរាជធានីភ្នំពេញ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ម្ចាស់ ឬនាយកក្រុមហ៊ុន៖**
លេខបញ្ជីពាណិជ្ជកម្ម៖
លេខអត្តសញ្ញាណសហគ្រាសក្នុង ប.ស.ស.៖
លេខគណនីធនាគារ៖
អាសយដ្ឋាន៖
ទូរស័ព្ទលេខ៖ អ៊ីមែល (E-mail)៖

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**តាមរយៈ** ៖ លោកប្រធាននាយកដ្ឋានអធិការកិច្ចការងារ
**កម្មវត្ថុ** ៖ សំណើសុំព្យួរកិច្ចសន្យាការងារ កម្មករនិយោជិតចំនួន នាក់ រយៈពេល ថ្ងៃ/ខែ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា ដោយមូលហេតុក្រុមហ៊ុនយើងខ្ញុំ ដូច្នេះ ក្រុមហ៊ុនយើងខ្ញុំស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន នាក់ ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន នាក់ រយៈពេល ថ្ងៃ/ខែ ដោយគិតចាប់ពីថ្ងៃទី ខែ រហូតដល់ថ្ងៃទី ខែ ឆ្នាំ២០២០។

ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុនបានព្រមព្រៀងផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិតចំនួន ដុល្លារអាមេរិក។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

.......... ថ្ងៃទី ..........ខែ ............. ឆ្នាំ២០២.....

ហត្ថលេខា និងត្រា

ម្ចាស់ ឬនាយក

សូមភ្ជាប់មកជាមួយ:
- កិច្ចព្រមព្រៀងអំពីនីតិវិធីទូទាត់ជាមួយកម្មករនិយោជិតចំនួន ៣ច្បាប់
- បញ្ជីរាយនាមកម្មករនិយោជិតដែលស្នើសុំព្យួរកិច្ចសន្យាការងារចំនួន ៣ច្បាប់ និង ជា Soft Copy (Ms Excel) ទៅ E-mail: suspension@nea.gov.kh
- បញ្ជីបើកប្រាក់ឈ្នួលចុងក្រោយមុនពេលស្នើសុំព្យួរកិច្ចសន្យាការងារ
- វិញ្ញាបនបត្រពាណិជ្ជកម្ម (ច្បាប់ថតចម្លង) ចំនួន ៣ច្បាប់
- ប័ណ្ណពន្ធប៉ាតង់ (ច្បាប់ថតចម្លង) ចំនួន ៣ច្បាប់
- អាជ្ញាប័ណ្ណទេសចរណ៍ (ច្បាប់ថតចម្លង) ចំនួន ៣ច្បាប់ (វិស័យទេសចរណ៍)
- វិញ្ញាបនបត្រចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន ក្នុង ប.ស.ស. ចំនួន ៣ច្បាប់ (បើមាន)

*ឧបសម្ព័ន្ធទី២៖ លិខិតស្នើសុំព្យួរកិច្ចសន្យាការងារ នៅខេត្ត*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ម្ចាស់ ឬនាយកក្រុមហ៊ុន៖**
លេខបញ្ជីពាណិជ្ជកម្ម៖
លេខអត្តសញ្ញាណសហគ្រាសក្នុង ប.ស.ស.៖
លេខគណនីធនាគារ៖
អាសយដ្ឋាន៖
ទូរស័ព្ទលេខ៖ អ៊ីមែល (E-mail)៖

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**តាមរយៈ** ៖ លោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ......
**កម្មវត្ថុ** ៖ សំណើសុំព្យួរកិច្ចសន្យាការងារ កម្មករនិយោជិតចំនួន នាក់ រយៈពេល ថ្ងៃ/ខែ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា ដោយមូលហេតុក្រុមហ៊ុនយើងខ្ញុំ ដូច្នេះ ក្រុមហ៊ុនយើងខ្ញុំស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន នាក់ ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន នាក់ រយៈពេល ថ្ងៃ/ខែ ដោយគិតចាប់ពីថ្ងៃទី ខែ រហូតដល់ថ្ងៃទី ខែ ឆ្នាំ២០២០។

ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុនបានព្រមព្រៀងផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិតចំនួន ដុល្លារអាមេរិក។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

.......... ថ្ងៃទី ..........ខែ ............ ឆ្នាំ២០២.....
ហត្ថលេខា និងត្រា
ម្ចាស់ ឬនាយក

សូមភ្ជាប់មកជាមួយ:
- កិច្ចព្រមព្រៀងអំពីនីតិវិធីទូទាត់ជាមួយកម្មករនិយោជិតចំនួន ៣ច្បាប់
- បញ្ជីរាយនាមកម្មករនិយោជិតដែលស្នើសុំព្យួរកិច្ចសន្យាការងារចំនួន ៣ច្បាប់ និង ជា Soft Copy (Ms Excel) ទៅ E-mail: suspension@nea.gov.kh
- បញ្ជីបើកប្រាក់ឈ្នួលចុងក្រោយមុនពេលស្នើសុំព្យួរកិច្ចសន្យាការងារ
- វិញ្ញាបនបត្រពាណិជ្ជកម្ម (ច្បាប់ថតចម្លង) ចំនួន ៣ច្បាប់
- ប័ណ្ណពន្ធប៉ាតង់ (ច្បាប់ថតចម្លង) ចំនួន ៣ច្បាប់
- អាជ្ញាប័ណ្ណទេសចរណ៍ (ច្បាប់ថតចម្លង) ចំនួន ៣ច្បាប់ (វិស័យទេសចរណ៍)
- វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន ក្នុង ប.ស.ស. ចំនួន ៣ច្បាប់ (បើមាន)

ឧបសម្ព័ន្ធទី៣៖ បញ្ជីរាយនាមកម្មករនិយោជិតដែលស្នើសុំព្យួរកិច្ចសន្យាការងារ

## បញ្ជីរាយនាមកម្មករនិយោជិតដែលស្នើសុំព្យួរកិច្ចសន្យាការងារ

**ក្រុមហ៊ុន**........................................................ **សកម្មភាពអាជីវកម្ម** ....................................................

**អាសយដ្ឋាន** ..........................................................................................................

រយៈពេលព្យួរកិច្ចសន្យាការងារ.............ថ្ងៃ/ខែ ចាប់ពីថ្ងៃទី.......ខែ........ឆ្នាំ២០២..... ដល់ថ្ងៃទី......ខែ.........ឆ្នាំ២០២.....

| ល.រ | ឈ្មោះកម្មករនិយោជិត | ភេទ | ថ្ងៃខែឆ្នាំកំណើត | បម្រើការនៅផ្នែក | លេខសមាជិក ប.ស.ស/ លេខរៀងក្នុងបញ្ជីកម្មករនិយោជិតដែលបានធ្វើបច្ចុប្បន្នភាពមកក្រសួង | លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | លេខទូរស័ព្ទ | ស្នាមមេដៃបញ្ជាក់របស់កម្មករនិយោជិត |
|---|---|---|---|---|---|---|---|---|
| 1 | ហេង កញ្ញា | ស | 30.09.1990 | ផ្នែកដេរ/ផ្នែករដ្ឋបាល | XXXXXXX-XXXXXXX-X | XXXXXXXXX | 0XX-XXXXXX | |
| 2 | | | | | | | | |
| 3 | | | | | | | | |
| 4 | | | | | | | | |

បានបញ្ចប់ត្រឹមលេខរៀងទី....

ថ្ងៃទី ...... ខែ ........ ឆ្នាំ២០២.....

ហត្ថលេខា និងត្រា

ម្ចាស់ ឬនាយក

**សម្គាល់៖**

-ក្រុមហ៊ុនត្រូវបោះត្រានៅគ្រប់ទំព័រលើបញ្ជីឈ្មោះនេះ

-ក្រុមហ៊ុនត្រូវផ្ញើបញ្ជីឈ្មោះនេះជា Excel File និង Scan បញ្ជីឈ្មោះដែលបោះត្រា និងមានស្នាមមេដៃ ជា PDF File មក E-mail: suspension@nea.gov.kh

## ឧបសម្ព័ន្ធទី៤៖ សេចក្តីណែនាំស្តីពីការស្នើសុំព្យួរកិច្ចសន្យាការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម

- ចូលទៅកាន់គេហទំព័រ ***https://suspension.mlvt.gov.kh***
- Log in ដោយបំពេញ Username និង Password (យកលេខទូរស័ព្ទលេខរៀងទី១ នៃបញ្ជីឈ្មោះកម្មករនិយោជិតដែលរោងចក្រ សហគ្រាស គ្រឹះស្ថានបានធ្វើបច្ចុប្បន្នភាពមកក្រសួង)

**ជំហានទី ១**

- បំពេញព័ត៌មានដូចជាឈ្មោះរោងចក្រ សហគ្រាស គ្រឹះស្ថាន, អាសយដ្ឋាន......
- ភ្ជាប់ (Upload) ឯកសារជា PDF ឬរូបភាព៖
  - ✓ វិញ្ញាបនបត្រពាណិជ្ជកម្ម
  - ✓ អាជ្ញាប័ណ្ណទេសចរណ៍
  - ✓ ប័ណ្ណពន្ធប៉ាតង់
  - ✓ វិញ្ញាបនបត្របញ្ជិកាពោងចក្រ សហគ្រាស គ្រឹះស្ថានក្នុង ប.ស.ស. (បើមាន)
  - ✓ កិច្ចព្រមព្រៀងអំពីនីតិវិធីទូទាត់ជាមួយកម្មករនិយោជិត
  - ✓ បញ្ជីបើកប្រាក់ឈ្នួលចុងក្រោយមុនពេលស្នើសុំព្យួរកិច្ចសន្យាការងារ

**ជំហានទី ២**

- បំពេញមូលហេតុនៃការស្នើសុំព្យួរកិច្ចសន្យាការងារ
- បំពេញចំនួនកម្មករនិយោជិតដែលត្រូវស្នើសុំព្យួរកិច្ចសន្យាការងារ និងរយៈពេលព្យួរកិច្ចសន្យាការងារ

**ជំហានទី ៣**

ជ្រើសរើសព្យួរកម្មករនិយោជិតទាំងអស់ ឬព្យួរមួយចំនួន

**ជំហានទី ៤**

ជ្រើសរើសឈ្មោះកម្មករនិយោជិតដែលត្រូវស្នើសុំព្យួរកិច្ចសន្យាការងារ ចេញពីបញ្ជីឈ្មោះដែលមានក្នុងប្រព័ន្ធ (ប្រសិនបើព្យួរមួយចំនួន)

**ជំហានទី ៥**

ចុចបញ្ជប់ការស្នើសុំព្យួរកិច្ចសន្យាការងារ

**ជំហានទី ៦**

- ចូលទៅទំព័រដើម ដើម្បី៖
  - ✓ ទាញយកលិខិតស្នើសុំព្យួរកិច្ចសន្យាការងារ ដើម្បីចុះហត្ថលេខា និងត្រៀមប្រគល់ជូនអធិការការងារពេលចុះពិនិត្យផ្ទៀងផ្ទាត់
  - ✓ ទាញយកបញ្ជីឈ្មោះកម្មករនិយោជិតដែលស្នើសុំព្យួរកិច្ចសន្យាការងារ ដើម្បីយកទៅស្វែងរក និងបំពេញព័ត៌មាន ដូចជាលេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ, លេខទូរស័ព្ទ, លេខប័ណ្ណសមាជិក ប.ស.ស. ...... និងឱ្យកម្មករនិយោជិតផ្តិតមេដៃបញ្ជាក់
- ក្រោយពេលអធិការការងារចុះពិនិត្យ និងមានស្នាមមេដៃត្រឹមត្រូវរបស់កម្មករនិយោជិត ត្រូវធ្វើបញ្ជីឈ្មោះនេះជា Excel File និង Scan បញ្ជីឈ្មោះដែលបោះត្រា និងមានស្នាមមេដៃនេះជា PDF File មក ***E-mail: suspension@nea.gov.kh***

ព័ត៌មានបន្ថែម៖

លោក ងួន សទ្ធី (017 300 708)   លោក លាង សុភ័គ (099 883 358)   កញ្ញា បេន ល័ក្ខណា (012 752 745)

*ឧបសម្ព័ន្ធទី៩៖ លិខិតជូនដំណឹងពីការបញ្ចប់ការព្យួរកិច្ចសន្យាការងារ (ចូលធ្វើការវិញ) នៅរាជធានីភ្នំពេញ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ម្ចាស់ ឬនាយកក្រុមហ៊ុន៖**
លេខបញ្ជីពាណិជ្ជកម្ម៖
លេខអត្តសញ្ញាណសហគ្រាសក្នុង ប.ស.ស.៖
លេខគណនីធនាគារ៖
អាសយដ្ឋាន៖
ទូរស័ព្ទលេខ៖ អ៊ីមែល (E-mail)៖

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**តាមរយៈ** ៖ លោកប្រធាននាយកដ្ឋានអធិការកិច្ចការងារ
**កម្មវត្ថុ** ៖ ការបញ្ចប់ការព្យួរកិច្ចសន្យាការងារ (ចូលធ្វើការវិញ)
**យោង** ៖ លិខិតអនុញ្ញាតព្យួរកិច្ចសន្យាការងារ លេខ ចុះថ្ងៃទី ខែ ឆ្នាំ២០២០

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា ដោយមូលហេតុក្រុមហ៊ុនយើងខ្ញុំ ដូច្នេះ ក្រុមហ៊ុនយើងខ្ញុំស្នើសុំបញ្ចប់ការព្យួរកិច្ចសន្យាការងារ (ចូលធ្វើការវិញ) ដល់កម្មករនិយោជិតចំនួន នាក់ ក្នុងចំណោមកម្មករនិយោជិតដែលបានសុំព្យួរសរុបចំនួន នាក់ ចាប់ពីថ្ងៃទី ខែ ឆ្នាំ២០២០ តទៅ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

.......... ថ្ងៃទី ..........ខែ ............ ឆ្នាំ២០២.....
ហត្ថលេខា និងត្រា
ម្ចាស់ ឬនាយក

សូមភ្ជាប់មកជាមួយ:
- លិខិតអនុញ្ញាតព្យួរកិច្ចសន្យាការងារ
- បញ្ជីរាយនាមកម្មករនិយោជិតដែលស្នើសុំបញ្ចប់ការព្យួរកិច្ចសន្យាការងារ (ចូលធ្វើការវិញ) ចំនួន ៣ច្បាប់ និងជា Soft Copy (Ms Excel) ទៅ E-mail: suspension@nea.gov.kh

*ឧបសម្ព័ន្ធទី៦៖ លិខិតជូនដំណឹងពីការបញ្ចប់ការព្យួរកិច្ចសន្យាការងារ (ចូលធ្វើការវិញ) នៅខេត្ត*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ម្ចាស់ ឬនាយកក្រុមហ៊ុន៖**
លេខបញ្ជីពាណិជ្ជកម្ម៖
លេខអត្តសញ្ញាណសហគ្រាសក្នុង ប.ស.ស.៖
លេខគណនីធនាគារ៖
អាសយដ្ឋាន៖
ទូរស័ព្ទលេខ៖ អ៊ីមែល (E-mail)៖

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**តាមរយៈ** ៖ លោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត........
**កម្មវត្ថុ** ៖ ការបញ្ចប់ការព្យួរកិច្ចសន្យាការងារ (ចូលធ្វើការវិញ)
**យោង** ៖ លិខិតអនុញ្ញាតព្យួរកិច្ចសន្យាការងារ លេខ ចុះថ្ងៃទី ខែ ឆ្នាំ២០២០

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន ឯកឧត្តមរដ្ឋមន្ត្រី មេត្តាជ្រាបថា ដោយមូលហេតុក្រុមហ៊ុនយើងខ្ញុំ ដូច្នេះ ក្រុមហ៊ុនយើងខ្ញុំស្នើសុំបញ្ចប់ការព្យួរកិច្ចសន្យាការងារ (ចូលធ្វើការវិញ) ដល់កម្មករនិយោជិតចំនួន នាក់ ក្នុងចំណោមកម្មករនិយោជិតដែលបានសុំព្យួរសរុបចំនួន នាក់ ចាប់ពីថ្ងៃទី ខែ ឆ្នាំ២០២០ តទៅ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តមរដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

សូម ឯកឧត្តមរដ្ឋមន្ត្រី មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

.......... ថ្ងៃទី ..........ខែ ............. ឆ្នាំ២០២.....
ហត្ថលេខា និងត្រា
ម្ចាស់ ឬនាយក

សូមភ្ជាប់មកជាមួយ:
- លិខិតអនុញ្ញាតព្យួរកិច្ចសន្យាការងារ
- បញ្ជីរាយនាមកម្មករនិយោជិតដែលស្នើសុំបញ្ចប់ការព្យួរកិច្ចសន្យាការងារ (ចូលធ្វើការវិញ) ចំនួន ៣ច្បាប់ និងជា Soft Copy (Ms Excel) ទៅ E-mail: suspension@nea.gov.kh

*ឧបសម្ព័ន្ធទី៧៖ លិខិតអនុញ្ញាតព្យួរកិច្ចសន្យាការងារ នៅរាជធានីភ្នំពេញ*

**អគ្គនាយកដ្ឋានការងារ**
**នាយកដ្ឋានអធិការកិច្ចការងារ**
លេខ:.........................កប/អក/អធក.

**ជម្រាបមក**
**លោក/លោកស្រី ម្ចាស់ ឬនាយក**..........................................

**កម្មវត្ថុ** ៖ ការអនុញ្ញាតព្យួរកិច្ចសន្យាការងារកម្មករនិយោជិត
**យោង** ៖ លិខិតលេខ........... ចុះថ្ងៃទី....... ខែ....... ឆ្នាំ២០២០ របស់ ...........

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប លោក/លោកស្រី ម្ចាស់ ឬនាយក ថា បន្ទាប់ពីបានពិនិត្យលើការស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ក្រសួងសម្រេចអនុញ្ញាតឱ្យព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន នាក់ ក្នុងចំនួនកម្មករនិយោជិតសរុប នាក់ រយៈពេលចំនួន ថ្ងៃ/ខែ ដោយគិតចាប់ពីថ្ងៃទី ខែ រហូតដល់ថ្ងៃទី ខែ ឆ្នាំ២០២ ។ ដើម្បីជួយសម្រួលដល់ជីវភាពប្រចាំថ្ងៃរបស់កម្មករនិយោជិតក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ លោក/លោកស្រី ម្ចាស់ ឬនាយក ត្រូវអនុវត្តការបើកប្រាក់ឧបត្ថម្ភរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមនីតិវិធីទូទាត់និងចំនួនដែលបានព្រមព្រៀងគ្នា។

ក្នុងករណី លោក/លោកស្រី ម្ចាស់ ឬនាយក ចង់ដំណើរការផលិតកម្ម ឬអាជីវកម្ម មុនកាលបរិច្ឆេទនៃការបញ្ចប់ការព្យួរកិច្ចសន្យាការងារ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឱ្យបានយ៉ាងតិច ២ថ្ងៃ (នៃថ្ងៃធ្វើការ) មុនថ្ងៃចូលធ្វើការ។

អាស្រ័យដូចនេះ សូម លោក/លោកស្រី ម្ចាស់ ឬនាយក បិទផ្សាយនូវលិខិតនេះ ជូនកម្មករនិយោជិតឱ្យបានជ្រាបគ្រប់ៗគ្នា។

សូម លោក/លោកស្រី ម្ចាស់ ឬនាយក ទទួលនូវសេចក្តីរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស.២៥៦.....
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២.....
**ត.ប. រដ្ឋមន្ត្រី**
**ប្រធាននាយកដ្ឋានអធិការកិច្ចការងារ**

**ចម្លងជូន:**
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងទេសចរណ៍ (សម្រាប់វិស័យទេសចរណ៍)
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងរ៉ែ និងថាមពល
- ធនាគារជាតិនៃកម្ពុជា
- អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បេឡាជាតិសន្តិសុខសង្គម
- ទីភ្នាក់ងារជាតិមុខរបរ និងការងារ
- រដ្ឋបាលរាជធានីភ្នំពេញ

*ឧបសម្ព័ន្ធទី៨៖ លិខិតអនុញ្ញាតព្យួរកិច្ចសន្យាការងារ នៅខេត្ត*

**មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត**.................

លេខ: ........................................

**ជម្រាបមក**

**លោក/លោកស្រី ម្ចាស់ ឬនាយក**...........................................

**កម្មវត្ថុ** ៖ ការអនុញ្ញាតព្យួរកិច្ចសន្យាការងារកម្មករនិយោជិត

**យោង** ៖ លិខិតលេខ........... ចុះថ្ងៃទី....... ខែ....... ឆ្នាំ២០២០ របស់ ...........

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប លោក/លោកស្រី ម្ចាស់ ឬនាយក ថា បន្ទាប់ពីបានពិនិត្យលើការស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ក្រសួងសម្រេចអនុញ្ញាតឱ្យព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន នាក់ ក្នុងចំនួនកម្មករនិយោជិតសរុប នាក់ រយៈពេលចំនួន ថ្ងៃ/ខែ ដោយគិតចាប់ពីថ្ងៃទី ខែ រហូតដល់ថ្ងៃទី ខែ ឆ្នាំ២០២ ។ ដើម្បីជួយសម្រួលដល់ជីវភាពប្រចាំថ្ងៃរបស់កម្មករនិយោជិតក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ លោក/លោកស្រី ម្ចាស់ ឬនាយក ត្រូវអនុវត្តការបើកប្រាក់ឧបត្ថម្ភរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមនីតិវិធីទូទាត់និងចំនួនដែលបានព្រមព្រៀងគ្នា។

ក្នុងករណី លោក/លោកស្រី ម្ចាស់ ឬនាយក ចង់ដំណើរការផលិតកម្ម ឬអាជីវកម្ម មុនកាលបរិច្ឆេទនៃការបញ្ចប់ការព្យួរកិច្ចសន្យាការងារ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឱ្យបានយ៉ាងតិច ២ថ្ងៃ (នៃថ្ងៃធ្វើការ) មុនថ្ងៃចូលធ្វើការ។

អាស្រ័យដូចនេះ សូម លោក/លោកស្រី ម្ចាស់ ឬនាយក បិទផ្សាយនូវលិខិតនេះ ជូនកម្មករនិយោជិតឱ្យបានជ្រាបគ្រប់ៗគ្នា។

សូម លោក/លោកស្រី ម្ចាស់ ឬនាយក ទទួលនូវសេចក្តីរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស.២៥៦.....

................... ថ្ងៃទី ខែ ឆ្នាំ២០២.....

**ត.ប. រដ្ឋមន្ត្រី**

**ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

ចម្លងជូន:

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងទេសចរណ៍ (សម្រាប់វិស័យទេសចរណ៍)
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងរ៉ែ និងថាមពល
- ធនាគារជាតិនៃកម្ពុជា
- អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បេឡាជាតិសន្តិសុខសង្គម
- ទីភ្នាក់ងារជាតិមុខរបរ និងការងារ
- រដ្ឋបាលខេត្ត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ម្ចាស់ ឬនាយកក្រុមហ៊ុន៖**
លេខបញ្ជីពាណិជ្ជកម្ម៖
លេខអត្តសញ្ញាណសហគ្រាសក្នុង ប.ស.ស.៖
លេខគណនីធនាគារ៖
អាសយដ្ឋាន៖
ទូរស័ព្ទលេខ៖ អ៊ីមែល (E-mail)៖

**សូមគោរពជូន**
**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកបេឡាជាតិសន្តិសុខសង្គម**

**កម្មវត្ថុ ៖** ការជូនដំណឹងអំពីការផ្អាកបង់ភាគទាន ប.ស.ស.
**យោង ៖** លិខិតអនុញ្ញាតព្យួរកិច្ចសន្យាការងារលេខ............ ចុះថ្ងៃទី ...... ខែ......ឆ្នាំ ....... របស់ ...........

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រតិភូ** មេត្តាជ្រាបថា ដោយក្រុមហ៊ុនយើងខ្ញុំបានទទួលការអនុញ្ញាតព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន នាក់ ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន នាក់ រយៈពេល ថ្ងៃ/ខែ ដោយគិតចាប់ពីថ្ងៃទី ខែ រហូតដល់ថ្ងៃទី ខែ ឆ្នាំ២០២ ដូច្នេះក្រុមហ៊ុនយើងខ្ញុំសូមផ្អាកបង់ភាគទាន ប.ស.ស. ក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រតិភូ** ជ្រាបអំពីការផ្អាកបង់ភាគទាន ប.ស.ស. របស់យើងខ្ញុំក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រតិភូ** មេត្តាទទួលនូវសេចក្តីគោរពអំពីខ្ញុំ។

.......... ថ្ងៃទី ..........ខែ ............ ឆ្នាំ២០២.....
ហត្ថលេខា និងត្រា
ម្ចាស់ ឬនាយក

សូមភ្ជាប់មកជាមួយ:
- លិខិតអនុញ្ញាតព្យួរកិច្ចសន្យាការងារ (ច្បាប់ថតចម្លង)
- បញ្ជីរាយនាមកម្មករនិយោជិតដែលស្នើសុំព្យួរកិច្ចសន្យាការងារ